THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
Superintendent

ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១

ជូនចំពោះ មាតាបិតា និងក្រុមគ្រួសារ របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

នៅពេលដែលយើងទន្ទឹងរង់ចាំឆ្នាំសិក្សាក្នុងពេលខាងមុខនេះ ខ្ញុំចង់បញ្ជាក់ម្តងទៀតនូវអ្វីៗដែលខ្ញុំបាននិយាយជាច្រើនដងមកហើយ៖ **គោលបំណងសម្រាប់ឆ្នាំសិក្សា ២០២១-២០២២ របស់យើង គឺស្វាគមន៍សិស្សទាំងអស់របស់យើងអោយត្រឡប់មករៀនក្នុងថ្នាក់វិញដោយសុវត្ថិភាព ចំនួន ៥ ថ្ងៃក្នុងមួយសប្តាហ៍ ចាប់ផ្តើមនៅថ្ងៃអង្គារ ទី៣១ ខែសីហា ឆ្នាំ២០២១ - *ដែលជាថ្ងៃចូលរៀនដំបូង*។** យើងដឹងថា ការត្រឡប់មករៀនក្នុងថ្នាក់វិញជាមួយមិត្តភក្តិ និងអ្នកអប់រំដែលយកចិត្តទុកដាក់ ជាឱកាសដ៏ល្អបំផុតដើម្បីជួយពួកគេឱ្យធូរស្រាល និងសះស្បើយពីផលប៉ះពាល់ដែលមានការរអន្តរាយដោយជម្ងឺខូវីដ-១៩ ដែលឆ្លងពាសពេញពិភពលោក។

នៅទីសន្និសីទកាសែតកាលពីថ្ងៃពុធកន្លងមកនេះ ខ្ញុំបានឈរក្បែរលោកអភិបាលក្រុង Jim Kenney ប្រធានសហព័ន្ធគ្រូបង្រៀននៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា Jerry Jordan ប្រធានសាខានៅហ្វីឡាដែលហ្វ្យ៉ានៃសមាគមរដ្ឋបាលសាលាប្រចាំរដ្ឋផិនស៊ីលវេនញ៉ា (Philadelphia Chapter of the Commonwealth Association of School Administrators) បណ្ឌិត Robin Cooper ប្រធានសាខាសហជីព 634 Nicole Hunt និង Royce Merriweather ប្រធានសមាគមប៉ូលីសសាលានៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា។ យើងរួមគ្នាបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នាចំពោះគោលបំណងនេះ។ ។

លោកអ្នកអាចមើលសន្និសីទសារព័ត៌មានពេញលេញនៅក្នុងគេហទំព័រនេះ៖ https://youtu.be/FSf4viDZkaI

ខណៈពេលដែលគោលបំណងនេះពឹងផ្អែកលើ មជ្ឈមណ្ឌលត្រួតពិនិត្យ និងការពារជម្ងឺ (CDC) និងក្រសួងសាធារណៈសុខាភិបាលនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ាដែលបន្ថយការតឹងតែងរាល់តម្រូវការនៃការនៅឆ្ងាយពីគ្នា នៅមានអ្វីៗជាច្រើនទៀតដែលផ្តល់ទំនុកចិត្តដល់យើង ថាយើងនឹងអាចចាប់ផ្តើមការសិក្សាក្នុងថ្នាក់វិញនារដូវស្លឹកឈើជ្រុះនេះដោយសុវត្ថិភាព រួមទាំង៖

- អត្រានៃការឆ្លងជម្ងឺមានកម្រិតទាប (និងចុះថយ) នៅទីក្រុងហ្វីឡាដែលហ្វ្យ៉ា
- បន្តនូវការបន្ថយការដាក់កម្រិតដែលទាក់ទងនឹងជម្ងឺខូវីដ-១៩ ទូទាំងក្រុង និងប្រទេស
- ការកើនឡើងនៃចំនួនមនុស្សពេញវ័យ និងសិស្សដែលទទួលការចាក់ថ្នាំបង្ការរោគ
- ចំនួនអ្នកវិជ្ជមានជម្ងឺខូវីដ-១៩ មានកម្រិតទាបនៅសាលារបស់យើង ចាប់តាំងពីយើងបានចាប់ផ្តើមឲ្យសិស្សចូលរៀនក្នុងថ្នាក់វិញ ក្នុងខែមីនា ឆ្នាំ២០២១ (ទាបជាង ១%) និង

- ការកើនឡើងនៃការគាំទ្រដែលគួរឱ្យកត់សម្គាល់នៅសាលា និងចំពោះសិស្សដែលយើងកំពុងរៀបចំផែនការដើម្បីដោះស្រាយផលប៉ះពាល់នៃជម្ងឺខូវីដ-១៩ ដែលប្រកបដោយសមធម៌។

លោកអ្នកអាចជួយយើងកែលម្អផែនការរបស់យើងបន្ថែមទៀតដោយចូលរួមក្នុងការស្ទង់មតិដែលចំណាយពេលប្រមាណ ១០ នាទី។ ការស្ទង់មតិដែលលោកអ្នកអាចចូលបំពេញ ត្រង់នេះ នឹងបិទនៅ ថ្ងៃសុក្រក្រោយ ទី២៨ ខែឧសភា វេលាម៉ោង ៥ ល្ងាច។ ខ្ញុំសំណូមពរឱ្យលោកអ្នកទាំងអស់បញ្ចេញសម្លេង និងផ្តល់មតិយោបល់។

សូមអរគុណចំពោះការគាំទ្ររបស់លោកអ្នក នៅពេលដែលយើងរៀបចំគម្រោងការណ៍ជាមួយគ្នាសម្រាប់ឆ្នាំសិក្សា ២០២១-២០២២ ឲ្យមានជោគជ័យ។

ដោយសេចក្តីស្មោះស្ម័គ្រ



William R. Hite Jr., Ed.D.
អគ្គនាយក
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា